ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការ
# "បញ្ជរសេវាសាធារណៈចល័តរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ"

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដំណឹងដល់និយោជក កម្មករនិយោជិត អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល អ្នកស្វែងរកការងារទាំងក្នុងប្រទេស និងក្រៅប្រទេស សិស្ស និស្សិត និងសាធារណជន ជ្រាបថា ដោយទទួលបានការគាំទ្រដ៏ខ្ពង់ខ្ពស់ពី **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** ក្រសួងបានប្រកាសដាក់ឱ្យដំណើរការ "បញ្ជរសេវាសាធារណៈចល័តរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ" តាមប្រព័ន្ធព័ត៌មានបច្ចេកវិទ្យារបស់ខ្លួនចំនួន **១៥សេវា** ជាពិសេស សេវាចុះឈ្មោះស្វែងរកការងារ (Job Seeker), សេវាចុះឈ្មោះស្វែងរកបុគ្គលិក (Job Provider), សេវាចុះឈ្មោះស្វែងរកការងារក្រៅប្រទេស (Overseas Job Seeker), សេវាចុះឈ្មោះសិក្សាជំនាញវិជ្ជាជីវៈ (Skill & TVET Enrollment), សេវាចុះឈ្មោះសមាជិក ប.ស.ស. (Social Security Registration), សេវាផ្តល់បណ្ណ/សៀវភៅការងារកម្មករនិយោជិតខ្មែរ (Cambodian Employment Book and Worker Card), សេវាតាមដានវឌ្ឍនភាពនៃសំណើនីមួយៗរបស់ក្រសួង (MLVT Public Service Tracking) និងប្រអប់បណ្តឹងអនាមិក (Anonymous Complaint Box) ដែលបើកឱ្យប្តឹងបុគ្គលណាមួយដោយមិនចាំបាច់បញ្ជាក់អត្តសញ្ញាណរបស់ខ្លួន។

ជាមួយនឹងបញ្ជរសេវាសាធារណៈចល័តនេះ ពិភពការងារ និងការបណ្តុះបណ្តាល ព្រមទាំងសេវាសាធារណៈផ្សេងៗ របស់ក្រសួងស្ថិតនៅក្នុងដៃរបស់សាធារណជន។ ក្នុងន័យនេះ សាធារណជន ជាពិសេស យុវជនដែលមានបំណងស្វែងរកការងារធ្វើទាំងក្នុងប្រទេស និងក្រៅប្រទេស អាចប្រើប្រាស់សេវានេះឱ្យបានទំលំទូលាយតាមរយៈបញ្ជរសេវាសាធារណៈចល័តនៅតាមផ្សារទំនើប ហាងកាហ្វេ ឬតាមរយៈ QR Code ខាងក្រោម។ បន្ថែមពីនេះ ក្រសួងសូមថ្លែងអំណរគុណចំពោះម្ចាស់ហាងកាហ្វេ ម្ចាស់ផ្សារទំនើប ធនាគារ ក្រុមហ៊ុនឯកជន សមាគមនិយោជក និងដៃគូពាក់ព័ន្ធទាំងអស់ដែលបានផ្តល់ការគាំទ្រ ក្នុងការផលិតបញ្ជរសេវាសាធារណៈចល័តនេះ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម និយោជក កម្មករនិយោជិត អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល អ្នកស្វែងរកការងារទាំងក្នុងប្រទេស និងក្រៅប្រទេស សិស្ស និស្សិត និងសាធារណជន ជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ១០រោច ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៥

https://mlvt.gov.kh

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩